MINISTRY OF HEALTH

No. 027 DGH

KINGDOM OF CAMBODIA

NATION - RELIGION - KING

Phnom Penh, Date: 5 / 06 / 2009

# The National Policy on Healthcare Waste Management in the Kingdom of Cambodia

**Introduction:**

The majority of activities associated with healthcare result in the production of waste that may lead to disability and death. Although a large fraction of healthcare waste is very similar to domestic solid waste, there are some healthcare wastes which must be handled and managed properly to reduce or eliminate the risk to health.

Medical waste is one of the most problematic components of solid waste management. Medical waste management in Phnom Penh City is very poor and as a consequence potentially harmful to public health and the environment. It is actually difficult to give precise numbers of people affected by improper management of medical waste. The number of hospitals, clinics, and health centers within the City has been fluctuated from year to year. As a result, the volume of medical waste can reach a top in case that the number of facilities and patients is dramatically increased.

The mismanagement of medical waste poses severe risks to people, especially waste handle workers, waste pickers (children), and the environment. It has been shown that more than 2,000 (survey report on medical waste in Phnom Penh, Ministry of Environment) waste pickers collect daily value of waste for selling at open dumpsite, the so-called Stung Mean Chey, to sustain their lives. These waste pickers can be injured by directly contact with contaminated sharps. Infections of Hepatitis B & C (HBV & HCV) and the human immunodeficiency virus (HIV) are of most concerned diseases in Cambodia. The Blacksmith Institute consequently has been supporting the Ministry of Environment (MOE) through Solid Waste and Hazardous Substances Management Office to conduct survey on medical waste management aiming at identifying, reducing, and preventing potentially risks to public health and environment.

**Goals:**

All healthcare wastes generated by every healthcare facility in Cambodia will be handled and managed such that the wastes will not have a negative impact on human health and on the environment.

**Objective:**

1-Ascertain that all wastes generated in the country are properly segregated, stored, collected, transported, treated and disposed in a safe and environmentally sound manner.

2-Institute strategies to minimize the quantities and risks associated with healthcare wastes.

3-Abolish the use of known toxic, hazardous compounds (such as mercury) in healthcare facilities.

4-Put into practice healthcare waste treatment technologies that are in agreement with international protocols, treaties and conventions such as the Basel Convention on hazardous wastes, Kyoto Protocol, and the Stockholm Convention on Persistent Organic Pollutants.

5-To institute training programs for all staff in healthcare facilities and routine supervision.

6-To develop and put into practice information, education and communication programs for the public on the importance of proper healthcare waste management.

7-To ensure that the management of healthcare wastes is in accordance with existing plans for the management of municipal solid wastes in the country.

**Minister of Health**

**Dr. MAM BUNHENG**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០២៧ អបស.មក

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០០៩

# គោលនយោបាយជាតិស្តីពីការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាពនៅព្រះរាជាណាចក្រកម្ពុជា

## សេចក្តីផ្តើម

សកម្មភាពភាគច្រើន ដែលទាក់ទងនឹងការថែទាំសុខភាព បណ្តាលឱ្យមានការកើតជាសំណល់ដែលអាចបង្កឱ្យមានជាពិការភាព និង មរណភាព ទោះបីជាសំណល់វេជ្ជសាស្ត្រមួយផ្នែកធំមានលក្ខណៈប្រហាក់ប្រហែលសំណល់រឹងតាមលំនៅដ្ឋានក៏ដោយ សំណល់វេជ្ជសាស្ត្រមួយចំនួន ត្រូវតែរៀបចំទុកដាក់ និងគ្រប់គ្រងត្រឹមត្រូវដើម្បីកាត់បន្ថយ រឺលុបបំបាត់ហានិភ័យសុខភាព។

សំណល់វេជ្ជសាស្ត្រជាសមាសភាពមួយនៅក្នុងការគ្រប់គ្រងសំណល់រឹងហើយដែលមានបញ្ហាច្រើនជាងផ្នែកដទៃ។ ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រនៅក្នុងរាជធានីភ្នំពេញនៅមានកំរិតទាបនៅឡើយដែលជាហេតុធ្វើឱ្យឥទ្ធិពលនៃសំណល់វេជ្ជសាស្ត្រអាចធ្វើឱ្យមានការប៉ះពាល់ដល់សុខភាពមនុស្ស និងបរិស្ថាន។ គេមិនអាចធ្វើការប៉ាន់ប្រមាណនូវចំនួនមនុស្សដែលបានរងគ្រោះដោយសារការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រមិនបានល្អបានឡើយ។ ចំនួនប៉ូលីគ្លីនិក និងគ្លីនិកនៅក្នុងរាជធានីភ្នំពេញមានការប្រែប្រួលជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ការកើនឡើងនៃបរិមាណសំណល់វេជ្ជសាស្ត្រមានកំរិតខ្លាំងនៅក្នុងករណីណាដែលមានការកើនឡើងនៃអត្រាអ្នកជំងឺ។

ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រមិនប្រកបដោយលក្ខណៈត្រឹមត្រូវ នោះអាចធ្វើឱ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពរបស់ប្រជាពលរដ្ឋ ជាពិសេសដល់កម្មករដែលទទួលបន្ទុកក្នុងការប្រមូល និងដឹកជញ្ជូន និងក្មេងអនាថាដើររើសសំរាម និងបរិស្ថាន។ តាមរបាយការណ៍បានគូសបញ្ជាក់ឱ្យឃើញថា មានប្រជាពលរដ្ឋក្រីក្រប្រមាណជា ២០០០ នាក់ (របាយការណ៍អង្កេតឆ្នាំ ២០០២ របស់ក្រសួងបរិស្ថាន) កំពុងប្រកបរបរចិញ្ចឹមជីវិតតាមរយៈការដើរប្រមូលសំរាមនៅទីលានស្ទឹងមានជ័យ។ ពួកគេទាំងនោះអាចទទួល រងរបួសដោយផ្ទាល់ពីការមុតជាមួយនឹងម្ជុលចាក់ថ្នាំដែលសំបូរទៅដោយជំងឺគ្រប់ប្រភេទ។ ជំងឺថ្លើមប្រភេទ បេ និងសេ និងជំងឺអេដស៍ ដែលជាប្រភេទជំងឺដែលកំពុងមានការរីករាលដាលយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ ដោយយល់ឃើញថា ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រនៅទីក្រុងភ្នំពេញមានសភាពមិនល្អប្រសើរទើបវិទ្យាស្ថាន Blacksmith បានជួយឧបត្ថម្ភដល់ក្រសួងបរិស្ថាន តាមរយៈការិយាល័យគ្រប់គ្រងសំណល់រឹង និងសារធាតុប្រកបដោយគ្រោះថ្នាក់ ក្នុងគោលបំណងធ្វើការសិក្សាស្រាវជ្រាវ

លើបញ្ហានៃការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រដើម្បីកំណត់កាត់បន្ថយ និងទប់ស្កាត់នូវគ្រោះថ្នាក់ទាំងឡាយដែលកើតមានឡើងដល់សុខភាពសាធារណៈ និងបរិស្ថាន។

**គោលបំណង**

រាល់សំណល់ពីសេវាថែទាំសុខភាពទាំងអស់ដែលបានមកពីគ្រប់មូលដ្ឋានថែទាំសុខភាពក្នុងព្រះរាជាណាចក្រកម្ពុជានឹងត្រូវ បានចាត់ចែង និងគ្រប់គ្រងដើម្បីធានាថា សំណល់ទាំងឡាយនោះនឹងមិនមានផលប៉ះពាល់ជាអវិជ្ជមានដល់សុខមាលភាពមនុស្ស និងបរិស្ថានឡើយ។

**គោលដៅ**

១-ធ្វើឱ្យប្រាកដថា គ្រប់សំណល់ដែលបានមកពីសេវាថែទាំសុខភាព នៅក្នុងប្រទេសទាំងអស់ ត្រូវបានគ្រប់គ្រងត្រឹមត្រូវៈ បានញែកចេញពីគ្នា. បានទុកដាក់. បានប្រមូល បានដឹកជញ្ជូន បានសម្លាប់មេរោគ និងបានបោះចោលក្នុងលក្ខណៈសុវត្ថិភាព និងដោយលក្ខណៈបរិស្ថានល្អ។

២-រៀបចំយុទ្ធសាស្ត្រដើម្បីកាត់បន្ថយនូវបរិមាណសំណល់ និងគ្រោះថ្នាក់ទាំងឡាយដែលបណ្តាលមកពីសំណល់សេវាថែទាំសុខភាព។

៣-លុបបំបាត់ចោលការប្រើសមាសធាតុពុល. សមាសធាតុគ្រោះថ្នាក់ជាថែដន្យ (ដូចជាបារ៉ត)នៅក្នុងមូលដ្ឋានសុខាភិបាល។

៤-អនុវត្តនូវបច្ចេកវិជ្ជាប្រព្រឹត្តិកម្មសំណល់ពីសេវាថែទាំសុខភាពទៅតាមពិធីសារអន្តរជាតិ សន្ធិសញ្ញា អនុសញ្ញាដូចជាអនុសញ្ញាក្រុងបាសែលស្តីពីសំណល់គ្រោះថ្នាក់ថៃដន្យ ពិធីសារក្រុងក្យូតូ និងអនុសញ្ញាស្តុកខូមស្តីពីភាពកខ្វក់ទាំងឡាយនៃសរីរាង្គមិនបំបែកធាតុស្ថិតនៅយូរក្នុងបរិស្ថាន។

៥-រៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីរាជការទាំងអស់នៅតាមមូលដ្ឋានថែទាំសុខភាព និងអភិបាលជាប្រចាំ

៦-បង្កើត និងដាក់ឱ្យអនុវត្តនូវកម្មវិធីប្រាស្រ័យទាក់ទង អប់រំ និងផ្តល់ព័ត៌មាន ដល់សាធារណជនស្តីពីសារសំខាន់នៃការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាពឱ្យបានត្រឹមត្រូវ។

៧-ធានាថា ការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាព គឺអនុលោមទៅតាមផែនការដែលមានស្រាប់សម្រាប់ការងារ គ្រប់គ្រងសំណល់រឹងរបស់ទីក្រុង នៅក្នុងប្រទេស ។៕

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

ក្រសួងសុខាភិបាល

**ម៉ម_ប៊ុនហេង**